# សុន្ទរកថា
# ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ក្នុងពិធីបើកសន្និបាតបូកសរុបការងារឆ្នាំ ២០១៧
# និងទិសដៅឆ្នាំ ២០១៨
# របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
# ថ្ងៃទី២៨ កុម្ភៈ ដល់ ២ មីនា ឆ្នាំ២០១៨

---------------------------

ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយស
ឯកឧត្តម លោកជំទាវ លោក លោកស្រី
អង្គសន្និបាតទាំងមូលជាទីមេត្រី!

សូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងសន្និបាតប្រចាំឆ្នាំរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នាព្រឹកនេះ។

អំបាញ់មិញ យើងបានស្តាប់នូវរបាយការណ៍បូកសរុបការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ ២០១៨ របស់ក្រសួងដែលអានដោយឯកឧត្តមរដ្ឋលេខាធិការ អ៊ុច បូរិទ្ធ។ របាយការណ៍នេះ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវសមិទ្ធផលទាំងឡាយ ដែលក្រសួងបានសម្រេចក្នុងការបន្តនិរន្តរភាព នៃនយោបាយការបរទេសកម្ពុជា ដោយចេះបត់បែនតបតនឹងការវិវឌ្ឍប្រែប្រួលដ៏ជ្រាលជ្រៅ និងស្មុគស្មាញនៃស្ថានការណ៍តំបន់ និងពិភពលោក ព្រមទាំងសមិទ្ធផលទាំងឡាយក្នុងការដ្ឋានកំណែទម្រង់ស្ថាប័ន ទាំងផ្នែករចនាសម្ព័ន្ធ របៀបរបប និងឥរិយាបទការងារ ការកសាងសមត្ថភាព ពង្រឹងវិជ្ជាជីវៈ និងការគ្រប់គ្រង។

នៅថ្ងៃទី២ ខែមីនា ខាងមុខនេះ នាឱកាសបិទសន្និបាត យើងនឹងមានកិត្តិយសបានទទួលស្វាគមន៍ និងបានត្រងត្រាប់ស្តាប់អនុសាសន៍របស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង តំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ថ្ងៃនេះ ខ្ញុំមានកិត្តិយសដោយបានថ្លែងនៅចំពោះមុខភ្ញៀវកិត្តិយស អ្នកការទូតចម្រុះវ័យ និងជំនាន់ បទពិសោធន៍ និងចំណេះដឹង ដើម្បីបង្ហាញពីគោលការណ៍ធំៗនៃនយោបាយការបរទេសរបស់កម្ពុជាយើង។

ឆ្នាំ២០១៧ ដែលកន្លងផុតទៅ មានអត្ថន័យសំខាន់ណាស់សម្រាប់ពិភពលោក សម្រាប់តំបន់ និងសម្រាប់កម្ពុជា។ វាជាឆ្នាំ ដែលជិតទៅដោយចរន្តធំៗ បង្កើតឡើងដោយរបត់នយោបាយថ្មីរបស់រដ្ឋការលោកប្រធានាធិបតី Trump ជាមួយនឹងទិសស្លោក "ផលប្រយោជន៍អាមេរិកមុនគេ (America First)" ការចាកចេញរបស់អង់គ្លេសពី EU (Brexit) និងការរៀបចំផ្ទៃក្នុង EU ឡើងវិញ ការបន្តងើបឡើងយ៉ាងប្រត្យក្សនៃប្រទេសចិន ការជំរុញដ៏ខ្លាំងក្លានូវគំនិតផ្តួចផ្តើមរបស់ប្រទេសធំៗ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការតភ្ជាប់នៅក្នុងតំបន់ និងដោយភាពតានតឹងតាមតំបន់នានា ពិសេសនៅតំបន់មជ្ឈឹមបូព៌ា។ វាក៏ជាឆ្នាំ ដែលសកលភាវូបនីយកម្ម និងការលូតលាស់ខាងផ្នែកបច្ចេកវិទ្យា បានបង្កើនពាណិជ្ជកម្ម និងភោគទ្រព្យនៅលើពិភពលោក។

ឆ្នាំ២០១៧ ក៏ជាឆ្នាំដ៏សំខាន់សម្រាប់ ASEAN ដែលបានប្រារព្ធខួប ៥០ឆ្នាំ របស់ខ្លួនក្នុងលក្ខណៈអធិកអធម និងមោទនភាពបំផុត។ អាស៊ានបានជំរុញគោលដៅកសាងសហគមន៍ផ្តោតលើការយកចិត្តទុកដាក់ចំពោះប្រជាជន និងយកប្រជាជនជាស្នូល ស្របតាម "ទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ"។ សហគមន៍សេដ្ឋកិច្ចអាស៊ានបានបោះជំហានយ៉ាងលឿនក្នុងការជំរុញសមាហរណកម្មសេដ្ឋកិច្ចពេញលេញ និងខាងផ្លូវច្បាប់របស់អាស៊ាន។ តំបន់អាស៊ានបានរីកចំរើនលូតលាស់ ហើយក៏បានរួមវិភាគទានបង្កើតឡើងនូវលក្ខណសម្បត្តិអំណោយផលដល់សន្តិភាព ស្ថិរភាព និងវិបុលភាពនៅអាស៊ីអាគ្នេយ៍។ ប៉ុន្តែគម្លាតអភិវឌ្ឍន៍ក្នុងចំណោមប្រទេសសមាជិកអាស៊ានខ្លួនឯងក៏នៅតែជាបញ្ហាប្រឈម។

យើងក៏បានមើលឃើញផងដែរថា ឆ្នាំ២០១៧ ជាឆ្នាំដែលមានភាពមិនច្បាស់លាស់ជាច្រើននៅលើពិភពលោក ជាមួយនឹងកត្តាអស្ថិរភាព និងការប្រឈមថ្មីដែលបានរីកដុះដាលឡើងលើណេសិរ្សជាច្រើន រួមមាន ការរីកឡើងនៃប្រជានិយម និងជ្រុលនិយម ការដើរថយក្រោយនៃពាណិជ្ជកម្មសេរី និងការវិលមកវិញនៃការគាំពារនិយម បដិវត្តន៍ឌីជីថល ក៏ដូចជាភាពស្មុគស្មាញនៃការប្រឈមចំពោះសន្តិសុខប្រពៃណី និងមិនប្រពៃណី ក្នុងនោះមានការប្រែប្រួលអាកាសធាតុ ការរីករាលដាលនៃជំងឺឆ្លង និងបទល្មើសបច្ចេកវិទ្យា ជាដើម។

ការប្រកួតប្រជែងឥទ្ធិពលគ្នា នៅក្នុងអាស៊ីអាគ្នេយ៍ ពីសំណាក់មហាអំណាចធំបំផុតទាំងពីរនៅលើពិភពលោក បានជះផលវិបាកខាងភូមិសាស្ត្រនយោបាយដ៏ជ្រាលជ្រៅមកលើតំបន់យើង។ ជម្លោះដើម្បីអធិបតេយ្យភាពដែនដីជាច្រើនមានការពាក់ព័ន្ធនឹងមហាអំណាច និងប្រទេសមានអំណាចធំៗនៅអាស៊ី។ ភាពតានតឹងនៅតែបន្តកើនឡើងនៅឧបទ្វីបកូរ៉េ ដោយសារការបន្តការសាកល្បងអាវុធបាញ់កាំជ្រួច និងកម្មវិធីនុយក្លេអ៊ែរ និងការបង្កើនការសមយុទ្ធយោធា ធ្វើឲ្យស្ថានភាពការណ៍តំបន់នេះ

នៅតែមានភាពផុយស្រួល បើទោះបីមានសញ្ញាវិជ្ជមានកើតឡើងដោយសារការខិតជិតគ្នារវាងកូរ៉េទាំងពីរនាពេលថ្មីៗនេះក៏ដោយ។

ខាងវិស័យសេដ្ឋកិច្ចវិញ ផលវិបាកដែលនៅសេសសល់ពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨ នៅបន្តជះឥទ្ធិពលអវិជ្ជមានមកលើការលូតលាស់របស់ពិភពលោក។ កត្តាមួយចំនួន ដូចជាការកើនឡើងនៃវិសមភាព ភាពតានតឹងសង្គម និងចលនាផ្លាស់ទីលំនៅ បានផ្គុំផ្សំគ្នាបង្កើតបានជាការប្រឈមខាងសន្តិសុខជាច្រើន តួយ៉ាង ភេរវកម្មនិងអំពើជ្រុលនិយម ឧក្រិដ្ឋកម្មបច្ចេកវិទ្យា និងការជួញដូរមនុស្ស។ គួរឲ្យព្រួយបារម្ភជាងនេះទៅទៀត គឺការងើបឡើងនៃតួអង្គមិនមែនរដ្ឋ ដែលបានគាស់រំលើងគ្រឹះនៃសណ្តាប់ធ្នាប់អន្តរជាតិដែលផ្អែកលើច្បាប់ ដោយព្យាយាមកាន់កាប់ដែនដីអធិបតេយ្យ ដើម្បីបង្កើតរដ្ឋឥស្លាមបែប ISIS នៅស៊ីរី អ៊ីរ៉ាក់ ហើយថ្មីៗនេះនៅទីក្រុងម៉ារ៉ាវី ប្រទេសហ្វីលីពីន ។

ជាការពិតហើយ សម័យកាលណាក៏មានភាពស្រពិចស្រពិលមិនច្បាស់លាស់របស់វាដែរ ប៉ុន្តែភាពស្រពិចស្រពិលដែលយើងជួបប្រទះនាពេលនេះ អាចបង្កគ្រោះថ្នាក់លើសសម័យកាលមុនៗទៅទៀត ។

### ឯកឧត្តម លោកជំទាវ លោក លោកស្រី

តើនឹងមានអ្វីខ្លះកើតឡើងនៅឆ្នាំ២០១៨ និងឆ្នាំទៅមុខទៀត? ច្បាស់ហើយថា ស្ថានការណ៍ភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចនឹងមានការផ្លាស់ប្តូរ នាំដល់ការប្រឈមថ្មី ហានិភ័យថ្មី អាទិភាពថ្មីមិនខាន។ អស្ថិរភាពនយោបាយ និងសន្តិសុខ ក្នុងកំរិតតំបន់ និងសកលនឹងបន្តគ្របដណ្តប់ស្ថានការណ៍ពិភពលោក ហើយជាហានិភ័យធំបំផុតសម្រាប់ឆ្នាំ២០១៨។

នៅតំបន់អាស៊ី មហាអំណាចធំៗ និងមធ្យម នឹងបន្តប្រកួតប្រជែង ឬចងសម្ព័ន្ធភាពដើម្បីទាញយកផលប្រយោជន៍ និងឥទ្ធិពលនយោបាយ យោធា និងសេដ្ឋកិច្ច។ តួអង្គមិនមែនរដ្ឋក៏នឹងខំរែករកនិងដណ្តើមតួនាទី ឬចំណែកនៅក្នុងអភិបាលកិច្ច និងផលប្រយោជន៍ ទោះជាតួអង្គនោះជាស្ថាប័នតំបន់ឬអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ចលនាសង្គម ក្រុមឧក្រិដ្ឋកម្ម ឬភេរវកម្ម សាជីវកម្មពហុជាតិក្តី។

អាស៊ានក៏ពិតជានឹងរងផលប៉ះពាល់ពីបញ្ហាភូមិសាស្ត្រនយោបាយដែលកើតចេញពីការប្រកួតប្រជែងអំណាច និងឥទ្ធិពលទាំងនេះ ហើយដែលនឹងជះឥទ្ធិពលដោយគ្មានសង្ស័យលើកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងដំណើរកសាងសហគមន៍ ការរក្សាឯកភាព និងមជ្ឈភាពរបស់ខ្លួនក្នុងទំនាក់ទំនងជាមួយដៃគូខាងក្រៅតំបន់ និងក្នុងនិម្មាបនកម្មតំបន់ ក៏ដូចជាក្នុងការបន្តការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចនិងទំនើបកម្ម ។

សម្រាប់យើងវិញ យើងនឹងត្រូវរកផ្លូវដ៏រៀងរៃបំផុតសំរាប់កម្ពុជា ដើម្បីជម្នះ និងឆ្លើយតបទៅនឹងនិន្នាការ និងការគំរាមកំហែង ដែលបានលេចចេញជារូបរាង និងដែលបង្ខំឲ្យយើងបន្សាំ និងសម្របខ្លួនជាប់ជាប្រចាំទៅនឹងតថភាព និងថាមវន្តថ្មី មិនថាពាក់ព័ន្ធនឹងបញ្ហានយោបាយ-សន្តិសុខ ពាណិជ្ជកម្ម ឬសហប្រតិបត្តិការលើវិស័យផ្សេងៗ ក្នុងចំណោមរដ្ឋសមាជិក ASEAN គ្នាឯង ឬជាមួយដៃគូខាងក្រៅនោះឡើយ។

ការជួបជុំអ្នកការទូតជាន់ខ្ពស់របស់យើងមកពីក្នុង និងក្រៅប្រទេស រយៈពេល៣ថ្ងៃនេះ នឹងអនុញ្ញាតឲ្យយើងផ្លាស់ប្តូរព័ត៌មាន និងទស្សនៈស្តីពីនិន្នាការ ការប្រឈម កាលានុវត្តភាព និងអាទិភាពនៃការអនុវត្តនយោបាយការបរទេសរបស់យើងក្នុងឆ្នាំ២០១៨ និងក្នុងបណ្តាឆ្នាំខាងមុខទៀត។ យើងនឹងរួមគ្នារកចម្លើយទៅនឹងសំណួរជាច្រើនពាក់ព័ន្ធនឹងសមត្ថភាព លទ្ធភាព និងព្រំដែនក្នុងការអនុវត្តគោលនយោបាយការបរទេសរបស់យើង ការប្រឹងប្រែងរិះរកនូវតុល្យភាពយុទ្ធសាស្ត្រដ៏សមស្របមួយរវាងផលប្រយោជន៍គោលរបស់ប្រទេសជាតិយើង និងផលប្រយោជន៍ផ្ទាល់នៃមហាអំណាចនានាដែលបានយកតំបន់អាស៊ី-ប៉ាស៊ីហ្វិកធ្វើជាទីលានប្រកួតប្រជែងអំណាច និងឥទ្ធិពល។ យើងនឹងពិភាក្សាគ្នាដើម្បីរកវិធីធ្វើយ៉ាងណាដើម្បីឲ្យ ASEAN អាចបន្តពង្រឹងឯកភាព មជ្ឈភាពរបស់ខ្លួន ឲ្យ ASEAN ក្លាយជាក្រុមប្រទេសមួយដែលមានសង្គតភាព និងការជឿជាក់ក្នុងការដោះស្រាយបញ្ហាតំបន់ និងពិភពលោក។

ការពិភាក្សារបស់យើង ក៏នឹងផ្តោតផងដែរទៅលើការអនុវត្តនូវការដ្ឋានកំណែទំរង់ស្ថាប័នដ៏ជ្រាលជ្រៅដែលបានចាប់ផ្តើមកាលពីជិត២ឆ្នាំមុននេះ។

កាលពីសប្តាហ៍មុន យើងបានសម្ពោធដាក់ឲ្យប្រើប្រាស់ និងដំណើរការនូវវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ និងអគារការិយាល័យបន្ថែម។ សមិទ្ធផលជារូបវន្តនេះគ្រាន់តែជាផ្នែកមួយនៃកំណែទំរង់របស់ក្រសួង សំដៅកែលំអ លក្ខខណ្ឌការងារ និងពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងក្រមសីលធម៌របស់អ្នកការទូតរបស់យើងតែប៉ុណ្ណោះ។

### ឯកឧត្តម លោកជំទាវ លោក លោកស្រី

ឥឡូវនេះ ខ្ញុំសូមចែករំលែកជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី នូវចក្ខុវិស័យ គោលការណ៍ និងគុណតម្លៃនានា ដែលនឹងដឹកនាំការងារការបរទេសរបស់យើង នៅចំពោះមុខការប្រឈមដែលយើងទាំងអស់គ្នាបានដឹង បានស្គាល់ និងភាពមិនច្បាស់លាស់ទាំងឡាយនៃសម័យកាលយើងនេះ។

យើងពិតជាមិនអាចផ្លាស់ប្តូរឋានៈរបស់កម្ពុជាយើងជាប្រទេសតូចបាននោះទេ តែយើងអាចផ្លាស់ប្តូរឋានៈ តួនាទី និងការចូលរួមរបស់យើងក្នុងកិច្ចការតំបន់ និងពិភពលោក ផ្អែកលើធន្ធៈ លទ្ធភាព សមត្ថភាពរបស់យើង និងផ្អែកលើផលប្រយោជន៍ស្នូលរបស់កម្ពុជាផ្ទាល់។

ក្នុងស្មារតីនេះ ខ្ញុំសូមលើកនូវការងារធំៗ ៥ ដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងត្រូវបំពេញស្របនឹងគោលការណ៍ និងគោលដៅនៃយុទ្ធសាស្រ្តការទូតរបស់យើង ។

*ការងារទីមួយ គឺការការពារផលប្រយោជន៍ជាតិ ជាពិសេសការពារឯករាជ្យ និងអធិបតេយ្យ។*

មាត្រា៥២ នៃរដ្ឋធម្មនុញ្ញរបស់យើង ចែងយ៉ាងច្បាស់ថា៖ "រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា... ។"

នៅក្នុងសុន្ទរកថាទទួលតំណែងកាលពីខែមេសា ឆ្នាំ២០១៦ ខ្ញុំបានថ្លែងនៅចំពោះមុខ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ថានឹងធានាបន្តនិរន្តរភាព ក្នុងការអនុវត្តគោលការណ៍គ្រឹះទាំងឡាយនៃនយោបាយការបរទេសកម្ពុជាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់យើង។ *ឥឡូវនេះហើយជាងពេលណាៗទាំងអស់ ការការពារឯករាជ្យ និងអធិបតេយ្យភាពរបស់យើង បានក្លាយទៅជាកាតព្វកិច្ចសំខាន់ និងចំបងជាងគេ។*

អធិបតេយ្យជាតិរបស់យើងត្រូវបានគំរាមកំហែង ដោយសាររដ្ឋាភិបាលបរទេសមួយចំនួន អង្គការក្រៅរដ្ឋាភិបាលបរទេស និងអង្គការអន្តរជាតិខ្លះ ដែលទទួលឥទ្ធិពលពីរដ្ឋាភិបាលបរទេសទាំងនោះ ជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់យើង។ អនុស្សាវរីយ៍ល្វីងជូរចត់នៃទសវត្សរ៍៧០ និង ៨០ រឹតតែបញ្ជាក់ពីភាពចាំបាច់ សម្រាប់កម្ពុជាក្នុងការកំណត់បន្ទាត់នយោបាយផ្ទាល់របស់ខ្លួន ដើម្បីការពារឯករាជ្យ អធិបតេយ្យភាព និងបូរណភាពដែនដីរបស់យើង។ ក្នុងឋានៈជាប្រទេសតូច និងកំពុងអភិវឌ្ឍ ការទប់ស្កាត់ចំពោះការជ្រៀតជ្រែកពីខាងក្រៅ តែងតែជាការតស៊ូដើម្បីការរស់រានមានជីវិតបន្តទៀតរបស់យើង។

រយៈពេលប៉ុន្មានខែចុងក្រោយនេះ កម្ពុជាយើងទទួលរងនូវការរិះគន់ ចោទប្រកាន់ពីរដ្ឋាភិបាលលោកខាងលិចមួយចំនួន ចំពោះអ្វីដែលពួកគេយល់ឃើញថា ជាការបង្ក្រាបពីសំណាក់រដ្ឋាភិបាលកម្ពុជាទៅលើបក្សប្រឆាំង សារព័ត៌មានឯករាជ្យ និងសង្គមស៊ីវិល។

គឺដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់គ្មានមូលដ្ឋាន និងជំហរលំអៀងនេះហើយ ទើបក្រសួងការបរទេសបានចេញផ្សាយឯកសារ "ប្រាប់ពីការពិត (To Tell The Truth)" កាលពីចុងឆ្នាំទៅមិញ ហើយនិងឯកសារមួយទៀតនាពេលថ្មីៗនេះ ដែលមានចំណងជើងថា "កម្ពុជា៖ ស្ថិរភាព និងការ

អភិវឌ្ឍជាអាទិភាព (Cambodia: Stability and Development First)"។ ឯកសារទាំងពីរនេះបាន ខិតខំបកស្រាយឲ្យឃើញអំពីការលំបាកដ៏ធំធេងរបស់កម្ពុជា ក្នុងការថែរក្សាសន្តិភាព និងជំរុញការ អភិវឌ្ឍ ក្នុងខណៈដែលមានការជ្រៀតជ្រែកជាប្រចាំពីបរទេស ដែលទទូច និងទាមទារឲ្យមានការផ្លាស់ប្តូរ ផ្តោះទៅរក "លិទ្ធិប្រជាធិបតេយ្យបរិសុទ្ធ និងល្អឥតខ្ចោះ" ដែលសូម្បីតែនៅប្រទេសបច្ចឹមទាំងនោះមិន ទាន់ទាំងសំរេចបានផង។ ការពិត វិធានការតាមផ្លូវច្បាប់សុទ្ធសាធទាំងឡាយដែលស្ថាប័នរដ្ឋអធិបតេយ្យ របស់យើងបានប្រកាន់យកគឺ យោងតាមភាពចាំបាច់ មានអត្ថន័យស្លាប់រស់សំរាប់ប្រទេសជាតិ ដើម្បីចាក ផុតពីការជ្រៀតជ្រែកពីខាងក្រៅ រារាំងការប៉ុនប៉ងដាក់បង្ខំឆន្ទៈបរទេសប្រឆាំងផលប្រយោជន៍ជាតិរបស់ យើង និងការទាញកម្ពុជាឲ្យធ្លាក់ក្នុងសម័យកាលខ្មៅងងឹតនៃសង្គ្រាម និងសោកនាដកម្មនៃអតីតកាល។ បរាជ័យក្នុងការប៉ុនប៉ងផ្លាស់ប្តូររបបតាមបែបបដិវត្តន៍ពណ៌ បាននាំឲ្យប្រទេសខ្លះប្រកាន់ឥរិយាបថបិទ ភ្នែកចំពោះតថភាពនៅកម្ពុជា ចំពោះសមិទ្ធផលដែលរាជរដ្ឋាភិបាលកម្ពុជាបានសំរេចក្នុងការនាំមកនូវ សន្តិភាពពេញលេញ ការដឹកនាំនយោបាយ សេដ្ឋកិច្ចបើកចំហ បែរឆ្ពោះទៅរកការនាំចេញ ការប្រកាន់ លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការលើកស្ទួយជីវភាពរស់នៅ និងការការពារសិទ្ធិសេរីភាពពលរដ្ឋ ព្រម ជាមួយនឹងការអនុវត្តដោយខ្ជាប់ខ្ជួននូវនីតិរដ្ឋ។

ពិតណាស់ យើងនឹងត្រូវតស៊ូតទៅមុខទៀត ដើម្បីការពារសិទ្ធិសំរេចលើវាសនាខ្លួន ដោយខ្លួន ឯង។ *កិច្ចការធំទី២ គឺការអនុវត្តនូវនយោបាយការបរទេសប្រកបដោយភាពបត់បែន រៀងវៃ តបទៅនឹង សម្ពាធភូមិសាស្ត្រនយោបាយ និងការប្រកួតប្រជែងដ៏គ្មានតឹងរបស់មហាអំណាចនានាដោយប្រកាន់ ខ្ជាប់នូវគោលការណ៍អព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ដូចមានចែងក្នុងមាត្រា៥៣ នៃរដ្ឋធម្មនុញ្ញ។*

កម្ពុជាប្រកាន់ភ្ជាប់នូវនយោបាយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និង ជាមួយប្រទេស ទាំងអស់នៅលើពិភពលោក។ កម្ពុជាប្រាថ្នាធ្វើជាមិត្តជាមួយប្រទេសទាំងអស់ ពិសេសជាមួយមហា អំណាចនានា ហើយគ្មានផលប្រយោជន៍អ្វីនឹងទាស់ទែង ចងជាសត្រូវជាមួយមហាអំណាចណាមួយ ឡើយ។ យើងយល់ថា គុណតម្លៃជាស្នូលនៃភាពជាដៃគូ គឺ "ការគោរពគ្នាទៅវិញទៅមក" និងការរាប់ រកគ្នាដោយស្មើភាព ស្មើសិទ្ធិ ទោះប្រទេសនោះ ធំ តូច មាន ក្រ មានរបបនយោបាយ ឬសាសនា វប្បធម៌ខុស គ្នាយ៉ាងណាក៏ដោយ យើងប្រកាន់គោលការណ៍សហប្រតិបត្តិការក្នុងភាពឈ្នះ-ឈ្នះ ដើម្បីការអភិវឌ្ឍ និងវិបុលភាពរួម និងផលប្រយោជន៍ដូចគ្នា។ យើងប្រកាន់ជំហរដ៏រឹងមាំរបស់យើងនៅក្នុងការការពារ រក្សាសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់។ ជំហរនេះហើយ ដែលយើងបានប្រកាន់ភ្ជាប់នៅក្នុងការ ដោះស្រាយបញ្ហាសមុទ្រចិនខាងត្បូង ដោយរក្សាអព្យាក្រឹតភាព គាំទ្រដល់ការដោះស្រាយជំលោះ ដោយភាគីពាក់ព័ន្ធផ្ទាល់ តាមមធ្យោបាយសន្តិវិធី និងផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិ ដែលទទួល

ស្គាល់ជាសកល ក្នុងស្មារតីនៃការរក្សាទំនាក់ទំនងដៃគូជាយុទ្ធសាស្ត្រអាស៊ាន-ចិន ដែលមានផលប្រយោជន៍ទៅវិញទៅមក ។ ជំហរដ៏មុឺងម៉ាត់របស់កម្ពុជា បានស្រោចស្រង់ និងបញ្ចៀសបានការចុះដុនដាបថែមទៀតនៃសភាពការណ៍ក្នុងតំបន់។ ទីបំផុត វាក៏ជាជំហរដែលភាគីពាក់ព័ន្ធសំខាន់ៗបានប្រកាន់យកផងដែរក្នុងដំណើរដោះស្រាយជម្លោះដោយសន្តិវិធី និងផ្អែកលើការវិវឌ្ឍជាវិជ្ជមាននានា ដែលទាំងអស់គ្នាសំរេចបាន។

យើងប្រកាន់យកនូវគោលនយោបាយការបរទេសច្បាស់លាស់ និងស្មារតីសហប្រតិបត្តិការអន្តរជាតិទូលាយ ដែលបានអនុញ្ញាតឲ្យយើងប្រមែប្រមូលបានការគាំទ្រ និងការផ្តល់វិភាគទានពីប្រទេសជាមិត្តសម្រាប់ជោគជ័យនៃការអភិវឌ្ឍរបស់យើង។ នេះហើយ ជាចក្ខុវិស័យ និងយុទ្ធសាស្ត្រយូរអង្វែងរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងការជំរុញឲ្យកម្ពុជាមានមុខមាត់ ចូលរួមពាក់ព័ន្ធក្នុងវេទិកាតំបន់ និងអន្តរជាតិនានាដ៏ច្រើនបំផុតដែលអាចធ្វើទៅបាន។

តទៅមុខ យើងនឹងបន្តធ្វើការជាមួយប្រទេសនានាដើម្បីកសាងភាពជាដៃគូជាមួយគ្នា ដ៏មានគុណភាព និងដើម្បីផលប្រយោជន៍ទៅវិញទៅមក។

ជាមួយប្រទេសខ្លះ យើងមានទស្សនៈខុសគ្នាលើបញ្ហាមួយចំនួន ដែលប្រការនេះជារឿងធម្មតាក្នុងទំនាក់ទំនងអន្តរជាតិ។ ប៉ុន្តែយើងនឹងបន្តធ្វើការជាមួយគ្នានៅលើវិស័យដែលមានផលប្រយោជន៍រួមដូចជា សហការប្រយុទ្ធប្រឆាំងនឹង ភេរវកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស ឧក្រិដ្ឋកម្មឆ្លងដែននានា ការសហការគ្នាក្នុងការឆ្លើយតបនឹងការគំរាមកំហែង ដែលកើតចេញពីការប្រែប្រួលអាកាសធាតុ ជំងឺឆ្លង។ល។ យើងក៏នឹងបន្តខិតខំធ្វើយ៉ាងណាឲ្យប្រទេសនានាយល់ និងយោគយល់ថាកម្ពុជានឹងបន្តកសាងប្រជាធិបតេយ្យ ដោយយកចិត្តទុកដាក់ខ្ពស់ទៅលើបរិការណ៍ និងលក្ខណៈពិសេសនៃប្រវត្តិសាស្ត្ររបស់កម្ពុជា។ យើងក៏នឹងខិតខំកាត់បន្ថយការខុសគ្នា ផ្អែកលើការគោរពគ្នាទៅវិញទៅមក។

យើងនឹងខិតខំធ្វើឲ្យទំនាក់ទំនងជាមួយប្រទេសជាមិត្តរបស់យើងដូចជាចិន ជប៉ុន បារាំង រុស្ស៊ី ឥណ្ឌា កូរ៉េខាងត្បូង អូស្ត្រាលី EU ។ល។ រីកចំរើនបន្តទៀត។ ប្រទេសទាំងនេះជាតួអង្គយុទ្ធសាស្ត្រ និងជាគ្រឹះដ៏សំខាន់សម្រាប់សន្តិភាព និងស្ថិរភាពពិភពលោក សម្រាប់យុត្តិធម៌ និងសហប្រតិបត្តិការក្នុងភាពឈ្នះ-ឈ្នះ។ កម្ពុជា ចងចាំជានិច្ចនូវគុណូបការៈចំពោះប្រទេសជាមិត្តក្នុងការជួយជ្រោមជ្រែង និងឧបត្ថម្ភ គាំទ្រដល់ការកសាងឡើងវិញ និងការអភិវឌ្ឍប្រទេសពីសំណាក់ប្រទេសទាំងនោះ។ ក៏ប៉ុន្តែ

យើងមិនអាចទទួលបានទេនូវការប្រើប្រាស់ជំនួយឧបត្ថម្ភដោយភ្ជាប់លក្ខខណ្ឌជាស្ពានសម្រាប់ជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា។

ជាមួយប្រទេសភូមិផងរបងជាមួយ យើងនឹងបន្តរក្សា និងពង្រឹងទំនាក់ទំនងមិត្តភាព ភាពជាអ្នកជិតខាងល្អ និងសហប្រតិបត្តិការជិតស្និទ្ធ សមតាមពាក្យចាស់លោកពោលថា "ជួញជិតប្រសើរជាងជួញឆ្ងាយ"។ យើងនឹងបន្តខិតខំដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ ដោយឈរលើគោលការណ៍ច្បាប់អន្តរជាតិ រួមមាន គោលការណ៍ខ្សែព្រំដែនមិនកែប្រែនៅពេលដែលបានឯករាជ្យ (Uti Possidetis) ជាដើម ដើម្បីកសាងតំបន់ព្រំដែនជាតំបន់សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ។

ជាមួយស្ថាប័ន និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ និងអង្គការអន្តរ-ជាតិនានា កម្ពុជាតាំងចិត្តជំរុញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ឲ្យកាន់តែរីកចំរើនថែមមួយកំរិតទៀត ព្រមទាំងខិតខំបង្កើនភាពជាតំណាងរបស់កម្ពុជានៅក្នុងស្ថាប័ន និងអង្គការអន្តរជាតិពហុវិស័យ។ យើងស្វាគមន៍អង្គការក្រៅរដ្ឋាភិបាលបរទេសទាំងអស់ដែលមានបំណងល្អសម្រាប់ការអភិវឌ្ឍកម្ពុជា និងភាពសុខសាន្តរបស់ប្រជាជនកម្ពុជា ដោយផ្អែកលើមូលដ្ឋាននៃការគោរពច្បាប់ និងអធិបតេយ្យកម្ពុជា។

## *កិច្ចការធំទី៣ គឺអនុវត្តការងារការទូតសេដ្ឋកិច្ច និងវប្បធម៌ ដើម្បីពង្រឹងសេដ្ឋកិច្ចជាតិយើង ។*

គ្មានសន្តិភាព គឺគ្មានការអភិវឌ្ឍ។ ហើយគ្មានការអភិវឌ្ឍ ក៏គ្មានសន្តិភាពស្ថិតស្ថេរដែរ ។

យើងទាំងអស់គ្នាបានស្គាល់គុណតំលៃនេះច្បាស់លាស់ហើយ។ គោលដៅរបស់យើងគឺសន្តិភាព និងវិបុលភាព មិនមែនសង្គ្រាម និងការបំផ្លិចបំផ្លាញឡើយ។ វិធីដ៏ល្អបំផុតដើម្បីសំរេចគោលដៅនេះ គឺការរៀបចំនយោបាយការបរទេសមួយ ដែលយកវិបុលភាពសេដ្ឋកិច្ចធ្វើជាស្នូល។ គ្មានប្រទេសណាបានទទួលជោគជ័យ ដោយមិនយកបញ្ហាសេដ្ឋកិច្ចធ្វើជារបៀបវារៈទី១ របស់ខ្លួនឡើយ ។

មិនមែនជាការចៃដន្យទេ ដែលកម្ពុជាបានក្លាយពីប្រទេសដែលបែកបាក់ និងច្បាំងគ្នាដោយក្រុមប្រដាប់អាវុធច្រើន មកជាប្រទេសដែលបានផ្សះផ្សារួបរួមជាតិ និងមានសន្តិភាពពេញលេញ។

មិនមែនជាការចៃដន្យទេ ដែលកម្ពុជាបានប្រែក្លាយខ្លួនពី "វាលពិឃាដ" មកជា ជើងឯកនៃកំណើនសេដ្ឋកិច្ច (Olympian of Growth) ដោយកាត់បន្ថយយ៉ាងគំហុកនូវអត្រានៃភាពក្រីក្រ ជានាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់ជាមធ្យមលើស៧% ជាង២០ឆ្នាំកន្លងមកនេះ។ ហើយក៏មិនមែនជា

ការចៃដន្យដែរ ដែលសន្តិភាព និងការអភិវឌ្ឍបានចាប់ដំណើរស្របពេលគ្នានោះ។ វាជាស្នូលនៃយុទ្ធ-សាស្ត្រ និងទស្សនវិជ្ជារបស់រាជរដ្ឋាភិបាលតាំងពីដំបូងមក។

ក្នុងស្មារតីនេះ យើងនឹងបន្តដំណើរលើផ្លូវនៃសេរីភាវូបនីយកម្មសេដ្ឋកិច្ច ពាណិជ្ជកម្មបើកចំហ និងសកលភាវូបនីយកម្ម។ យើងនឹងខិតខំជំរុញការចរចាស្តីពីកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) ប្រកបដោយគុណភាពខ្ពស់ ហើយដែលអាចទប់ទល់នឹងកំលាំងគាំពារនិយម និងជំរុញពាណិជ្ជកម្មពហុភាគីជាមួយអង្គការពាណិជ្ជកម្មពិភពលោក។

យើងក៏នឹងត្រូវរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍យ៉ាងណា ដើម្បីទាញយកផលប្រយោជន៍ពីគំនិតផ្តួចផ្តើមសំខាន់ៗ រួមមាន "ខ្សែក្រវ៉ាត់ និងផ្លូវ" របស់ចិន, "ការពង្រីកភាពជាដៃគូដើម្បីហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាព" និង"យុទ្ធសាស្ត្រ ឥណ្ឌូ-ប៉ាស៊ីហ្វិក" របស់ជប៉ុន "គោលនយោបាយសកម្មភាពឆ្ពោះទៅបូព៌ា" របស់ឥណ្ឌា "គោលនយោបាយភាគខាងត្បូងថ្មី" របស់សាធារណរដ្ឋកូរ៉េ ដែលអាចបំពេញឲ្យគ្នាទៅវិញទៅមកជាមួយនឹង"ផែនការមេស្តីពីការតភ្ជាប់អាស៊ាន(MPAC) ២០២៥" របស់សហគមន៍យើង។ យើងត្រូវចេះប្រើប្រាស់យន្តការសហប្រតិបត្តិការនានា តួយ៉ាងយន្តការសហប្រតិបត្តិការមេគង្គទាំង៥ ជាពិសេសគឺ មេគង្គ-ឡានឆាង (MLC) និងស្ថាប័នហិរញ្ញវត្ថុតំបន់ ព្រមទាំងវេទិកាពហុភាគីសំខាន់ៗដូចជា កិច្ចប្រជុំអាស៊ី-អឺរ៉ុប(ASEM) កិច្ចសន្ទនាស្តីពីសហប្រតិបត្តិការអាស៊ី (ACD) និងសន្និសីទស្តីពីអន្តរសកម្មភាពនិងការកសាងទំនុកចិត្តនៅអាស៊ី(CICA) ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងលើកស្ទួយកិត្យានុភាពកម្ពុជាលើឆាកអន្តរជាតិ។

អ្នកការទូតរបស់យើងនៅក្រៅប្រទេស មានភារកិច្ចជួយផ្សព្វផ្សាយពីភាពប្រកួតប្រជែងរបស់ប្រទេសយើង និងជួយលើកស្ទួយកម្ពុជាអោយក្លាយជាគោលដៅពេញនិយមសម្រាប់ឲ្យគេបោះទុនវិនិយោគ និងធ្វើទេសចរណ៍។

ព្រមជាមួយគ្នានេះ យើងក៏ត្រូវបន្តគិតគូរដល់សុខទុក្ខរបស់ពលករយើងដែលកំពុងធ្វើការងារនៅប្រទេសមួយចំនួន ពិសេសនៅប្រទេសថៃ កូរ៉េខាងត្បូង ម៉ាឡេស៊ី។ ស្ថានទូត និងស្ថានអគ្គកុងស៊ុលរបស់យើង ត្រូវប្រឹងប្រែងជួយដល់ពលករឲ្យពួកគាត់ទៅធ្វើការដោយស្របច្បាប់ ជួយប្រឹក្សាផ្លូវច្បាប់ ដោយសហការជាមួយស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋម្ចាស់ផ្ទះ ក្នុងការដោះស្រាយបញ្ហាប្រឈមនានាក្នុងគោលបំណងបញ្ចៀសការកេងប្រវ័ញ្ចគ្រប់បែបយ៉ាង និងផ្តល់សេវា និងជំនួយឧបត្ថម្ភដល់ពួកគាត់នៅពេលចាំបាច់។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

*ការងារធំទី ៤ គឺការចូលរួមអោយកាន់តែសកម្មថែមទៀតដល់បុព្វហេតុ សន្តិភាព ស្ថិរភាព និងការប្រយុទ្ធនឹងការប្រឈមនានានៃពិភពលោក។*

ជាប្រទេសតូចដែលទើបបានសន្តិភាពមិនយូរប៉ុន្មាន យើងកំពុងតែខំប្រឹង ជំនះការប្រឈមនានាក្នុងការអភិវឌ្ឍប្រទេសខ្លួន ដែលជាការប្រឈមវិលវល់មិនចេះចប់ ដូចជាមហន្តរាយពាក់ព័ន្ធនឹងការប្រែប្រួលធាតុអាកាស ឧក្រិដ្ឋកម្មឆ្លងដែន ឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ការគំរាមកំហែងមិនមែនប្រពៃណីជាដើម។

ប៉ុន្តែក្នុងនាមជាប្រទេសដែលបានឆ្លងកាត់ទុក្ខវេទនានៃសង្គ្រាមច្រើនទសវត្សរ៍ យើងបានរួមវិភាគទានដ៏សំខាន់ដល់សន្តិភាពពិភពលោក។

យើងមានមោទនភាពក្រៃលែងចំពោះការរួមចំណែករបស់កងកំលាំងរបស់យើងក្នុងបេសកកម្មរក្សាសន្តិភាពរបស់អ.ស.ប ។ ពីប្រទេសមួយដែលទទួលកងទ័ពមួកខៀវមកជួយរក្សាសន្តិភាព កម្ពុជាបានក្លាយជាប្រទេសដែលបញ្ជូនកងទ័ពរបស់ខ្លួនទៅចូលរួមបេសកកម្មរក្សាសន្តិភាពនៅប្រទេសស៊ូដង់ ស៊ូដង់ខាងត្បូង លីបង់ អាហ្វ្រិកកណ្តាល ឆាដ ស៊ីរី ម៉ាលី និងស៊ីព្រ៍ ។ ចាប់ពីឆ្នាំ ២០០៦ ដល់បច្ចុប្បន្ន យើងបានបញ្ជូនកងទ័ពចំនួន ៥.១៧២នាក់ ក្នុងនោះមានស្រ្តី ២៣០នាក់ ទៅចូលរួមបេសកកម្មខាងលើនេះ ហើយសព្វថ្ងៃ ទ័ពយើង៨១៣នាក់ កំពុងប្រតិបត្តិការក្នុងប្រទេសចំនួន៥។ បេសកកម្មទាំងនេះ ជាបេសកកម្មប្រកបដោយហានិភ័យ និងគ្រោះថ្នាក់។ ទ័ពយើងក៏បានពលីជីវិតក្នុងពេលបំពេញបេសកកម្មក្រោមធ្ង់ត្រអង្គការសហប្រជាជាតិ ជាការពលីដើម្បីបុព្វហេតុនៃការជួយសង្គ្រោះប្រទេសទីទៃ ប្រជាជនទីទៃ ឲ្យទទួលបានសន្តិភាព និងចាកផុតពីទុក្ខវេទនានៃសង្គ្រាម និងការបំផ្លិចបំផ្លាញ ។

យើងក៏នឹងផ្តោតកិច្ចសហប្រតិបត្តិការរបស់យើងជាមួយសហគមន៍អន្តរជាតិ និងស្ថាប័នរបស់អង្គការសហប្រជាជាតិ ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ដែលក្នុងនោះ យើងបានបន្ថែមគោលដៅទី១៨ ស្តីពីសកម្មភាពមីន ស្របតាមស្ថានការណ៍ជាក់ស្តែងរបស់កម្ពុជា។

ភេរវកម្ម និងលទ្ធិជ្រុលនិយមប្រកបដោយហឹង្សា គឺជាគ្រោះថ្នាក់សំរាប់គ្រប់ប្រទេសទាំងអស់។ ការប៉ុនប៉ងកាន់កាប់ទីក្រុង Marawi នៃប្រទេសហ្វីលីពីន បានបង្ហាញអោយឃើញថា អង្គការភេរវកម្មបានខិតខំពង្រីកវត្តមានរបស់គេនៅគ្រប់ទិសទី ពិសេសនៅអាស៊ីអាគ្នេយ៍។ ក្នុងចំណោមវិធានការទប់ស្កាត់នឹងការរីករាលដាលនៃចលនានេះ ការដោះស្រាយហេតុផលឫសគល់នៃភេរវកម្ម និងអំពើជ្រុល-និយម និងការលើកស្ទួយ "ការនិយមកណ្តាល" (moderation) គឺជាការចាំបាច់។ កម្ពុជាមានមោទនភាព

ជាមួយនឹងការអនុវត្ត "ការទូតសាសនា" របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបានលើកតំកើងសុខុដុមនីយកម្ម និងសហវិជ្ជមានដ៏ជោគជ័យរវាងសាសនាខុសៗគ្នានៅកម្ពុជា។

ឯកឧត្តម លោកជំទាវ លោក លោកស្រី,

ខ្ញុំបានសង្ខេបនូវទស្សនៈរបស់ខ្ញុំស្តីពីគោលការណ៍ និងការងារធំៗនៃនយោបាយការបរទេសរបស់កម្ពុជា។ ប៉ុន្តែយើងក៏មិនអាចអនុវត្តបានដោយជោគជ័យនូវគោលនយោបាយការបរទេសនេះឡើយ បើប្រសិនជាយើងគ្មានអង្គអ្នកការទូតដ៏ចំណានទេនោះ ។

ប្រការនេះបាននាំឲ្យយើងឈានទៅដល់ការងារធំទី៥ របស់យើងគឺ ការបន្តការដ្ឋានកំណែទំរង់ស្ថាប័ននៅក្នុងក្រសួង ដើម្បីរៀបចំអង្គអ្នកការទូតប្រកបដោយវិជ្ជាជីវៈ ស្នេហាជាតិ សកម្ម និងមានសមត្ថភាព ។

ជិត២ឆ្នាំមុន ពេលចូលមកកាន់តំណែងនេះ ខ្ញុំបានចង្អុលរៀបរាប់អំពីកំណែទំរង់ដ៏ចាំបាច់នានា ដែលត្រូវសំរេច ដើម្បីឲ្យអ្នកការទូត និងមន្ត្រីយើងបំពេញបេសកកម្ម និងភារកិច្ចបំរើ និងការពារផលប្រយោជន៍ប្រទេសជាតិបានប្រសើរជាង មានប្រសិទ្ធិភាពជាង និងជោគជ័យជាង ។

ការប្រែប្រួលដ៏ជ្រាលជ្រៅ ស្មុគស្មាញ ហើយដែលពិបាកប៉ាន់ស្មានបាននៃស្ថានការណ៍តំបន់ និងពិភពលោក កាន់តែតម្រូវឲ្យកម្ពុជាមានអង្គអ្នកការទូត មន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញដ៏មានសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងការប្រឈមថ្មីៗ ។ ក្នុងស្មារតីនេះ យើងនឹងត្រូវខិតខំកសាងនិងពង្រឹងសមត្ថភាពទូលំទូលាយរបស់មន្ត្រីការទូត ដើម្បីប្រែក្លាយក្រសួងការបរទេសរបស់យើងឲ្យទៅជាស្ថាប័នប្រកបដោយឋាមភាព និងភាពប៉ិនប្រសព្វ ។

យើងបានរៀបចំកែសំរួលរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួង ដែលឆ្លើយតបដោយប្រសិទ្ធិភាពជាងទៅនឹងតម្រូវការការងារ ។

យើងទើបសម្ពោធអគារ និងដាក់ឲ្យដំណើរការវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ដែលនឹងអាចបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព និងវិជ្ជាជីវៈរបស់អ្នកការទូតយើង។

យើងក៏កំពុងធ្វើសមាហរណកម្មក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន ចូលមកក្នុងក្រសួងដើម្បីបន្តបេសកកម្មជាក្រុមវិភាគ និងព្យាករណ៍ ព្រមទាំងផ្តល់យោបល់ និងទស្សនៈស្តីពីកិច្ចការនយោបាយ ដោយឲ្យក្រុមនេះបានប្រឡូកដោយផ្ទាល់ និងជាប្រចាំក្នុងកិច្ចការការបរទេស។

យើងបានបង្កើតរបបប្រាក់រង្វាន់ប្រចាំខែ ស្របតាមស្មារតីនៃការរួមចំណែក និងចែករំលែក។ យើងបានគិតគូរដល់ការតំឡើងប្រាក់បៀវត្សរ៍ និងឈ្នួលផ្ទះដល់មន្ត្រីការទូតយើងនៅបរទេស ដើម្បីសម្រួលការរស់នៅ និងបំពេញការងារអោយមានភាពថ្លៃថ្នូរជាង។ យើងបានកសាងអគារបន្ថែម ដើម្បីផ្តល់ភាពងាយស្រួលជាង និងប្រសើរជាង ក្នុងការបំពេញការងាររបស់មន្ត្រី បុគ្គលិករបស់យើង។

យើងបានកែប្រែដំណើរការ និងនីតិវិធីជ្រើសរើសមន្ត្រីកាន់តំណែងសំខាន់ៗឈរលើគុណសម្បត្តិ សមត្ថភាព តម្លាភាព និងសមធម៌។ ធ្វើការសាកល្បង និងបំប៉នសមត្ថភាព មន្ត្រីការទូតមុនចេញទៅក្រៅប្រទេស ដើម្បីធ្វើយ៉ាងណាអោយអ្នកការទូតយើងបំពេញការងារ និងបេសកកម្មបានស័ក្តិសម និងជោគជ័យ។

តែយើងក៏ត្រូវបន្តកំណែទំរង់ទាំងនេះទៅមុខថែមទៀតដែរ។

តទៅមុខ យើងនឹងបន្ថែមលក្ខណៈសម្បត្តិសំរាប់មន្ត្រីការទូតដែលត្រូវទៅក្រៅ។ សមត្ថភាពភាសាអង់គ្លេសខ្ពស់ និងច្បាស់លាស់ ដែលសមស្របតាមតម្រូវការវិជ្ជាជីវៈ នឹងក្លាយជាលក្ខខណ្ឌចាំបាច់ ។ ការចេះភាសាផ្សេងថែមទៀត នឹងត្រូវស្វាគមន៍ និងលើកទឹកចិត្ត។ អ្នកការទូតយើងចាំបាច់ត្រូវក្តាប់អោយបាននូវបន្ទាត់នយោបាយរបស់រាជរដ្ឋាភិបាល មានចំណេះដឹងទូលំទូលាយអំពីច្បាប់ និងទំនៀមទម្លាប់អន្តរជាតិ មានសមត្ថភាពចរចា តតាំង ឆ្លើយតបជាមួយអ្នកការទូតបរទេស អ្នកកាសែត និងសាធារណៈមតិ ។ ទន្ទឹមនេះយើងត្រូវបន្តប្រែក្លាយពីការងារការទូតប្រពៃណី ទៅជាការងារការទូតទំនើប ផ្តោតការយកចិត្តទុកដាក់លើវិស័យសេដ្ឋកិច្ចទេសចរណ៍ និងវប្បធម៌ ។

ខាងលើនេះគ្រាន់ជាទស្សនៈរបស់ខ្ញុំ អំពីការងារធំៗ៥យ៉ាង ដែលថ្នាក់ដឹកនាំ មន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ យើងត្រូវយកជាមូលដ្ឋាន ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់ និងរិះរកគំនិត វិធានការ មធ្យោបាយដើម្បីប្រែក្លាយទស្សនៈនេះឲ្យទៅជាការអនុវត្តជាក់ស្តែង។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី

ខ្ញុំពេញចិត្តនឹងសមិទ្ធផលដែលយើងសម្រេចបានក្នុងឆ្នាំកន្លងមក ទាំងលើសមរភូមិការទូតទ្វេភាគី និងពហុភាគី ទាំងលើការដ្ឋានកំណែទំរង់ស្ថាប័នក្រសួងរបស់យើង។

ខ្ញុំដឹងថា លទ្ធផលដែលទទួលបានពីការប្រឹងប្រែងរួមគ្នានេះ មិនទាន់ដោះស្រាយគ្រប់បញ្ហាដែលយើងជួបប្រទះក្នុងការបំពេញបេសកកម្មរបស់យើងនៅឡើយទេ។ ការជួបជុំគ្នា ៣ថ្ងៃនេះ នឹងបើកឱកាសអោយយើងធ្វើការវាយតម្លៃ ពិភាក្សា បញ្ចេញយោបល់ ផ្តល់គំនិតថ្មីៗថែមទៀត ដើម្បីយើងបន្តកសាង

ក្រសួង កសាងអ្នកការទូតដែលមានកម្រិតវិជ្ជាជីវៈ និងសមត្ថភាពខ្ពស់ ស្វាមីភក្តិចំពោះជាតិមាតុភូមិ ការពារភាពថ្លៃថ្នូរ និងផលប្រយោជន៍គោលរបស់ប្រទេស និងប្រជាជនយើង។

ខ្ញុំសូមសំដែងនូវអំណរគុណដ៏ស្មោះស្ម័គ្របំផុតចំពោះថ្នាក់ដឹកនាំ មន្ត្រីការទូត មន្ត្រី បុគ្គលិក ទាំងអស់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលបានគាំទ្រដំណើរការកែទំរង់ និង បានបំពេញដោយពុំខ្លាចនឿយហត់នូវភារកិច្ចដ៏លំបាក ប៉ុន្តែឧត្តុង្គឧត្តមក្នុងការបំរើជាតិមាតុភូមិ។

ខ្ញុំសូមថ្លែងអំណរគុណ ដ៏ស្មោះចំពោះ ឯ.ឧ ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ឯ.ឧ កើត រិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និង លោកជំទាវ តឹករ៉េត កំរ៉ុង រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដែលបានលះបង់ពេលវេលាដ៏មានតំលៃមកធ្វើបទឧទ្ទេសនាមស្តីពី "ចលនាបដិវត្តន៍ពណ៌នៅកម្ពុជា" "វិធានការច្បាប់ដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជា" និង "យុទ្ធសាស្ត្រជំរុញទីផ្សារ និងប្រព័ន្ធអនុគ្រោះពន្ធលើ កម្ពុជា" ដែលជាប្រយោជន៍ដល់ការយល់ដឹងកាន់តែទូលាយ កាន់តែច្បាស់ ដល់អ្នកការទូត និងមន្ត្រី យើងនៅទីនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៧ និងទិសដៅការងារ ឆ្នាំ២០១៨ និងសូមអោយការពិភាក្សាផ្លាស់ប្តូរយោបល់របស់យើងទទួលបានផ្លែផ្កាល្អប្រសើរ។

*សូមអរគុណ។*